# ពុទ្ធិសែន នាងកង្រី

## ភាគបញ្ចប់

ពុទ្ធិសែននៅសោយរាជ្យនគរយក្សយ៉ាងសុខសាន្ត មួយឆ្នាំក្រោយមកព្រះនាងកង្រីក៏ប្រសូត្របានបុត្រមួយអង្គយ៉ាងស្រស់ត្រកាល។ ព្រះអង្គពុទ្ធិសែនបានប្រជុំអស់ហោរាដើម្បីរកឈ្មោះដាក់ឲ្យបុត្រ ហើយដែលបុត្រនោះមានព្រះនាមថា ព្រះពុទ្ធិសែននរេន្ទ្រ។ លុះបុត្រទីមួយគម្រប់៣ឆ្នាំព្រះនាងកង្រីក៏ប្រសូតបុត្រមួយទៀត ហើយឲ្យឈ្មោះជុំ សែន។ នៅរាត្រីមួយព្រះអង្គពុទ្ធិសែនបានយល់សុបិន្តឃើញព្រះមាតា និងម្ដាយធំទាំង១១នាក់ ព្រះអង្គស្ទុះងើបទាំងកំពុងផ្ទុំលក់ ពេលនោះព្រះអង្គក៏នឹកឃើញនូវទុក្ខលំបាករបស់ព្រះមាតា ទាំងពាក្យផ្ដែផ្ដាំរបស់ព្រះមាតាដែលរៀបចេញមក គិតឃើញសព្វគ្រប់ ព្រះអង្គក៏ងើប ហើយដើរចុះឡើងៗ ព្រះនាងកង្រីភ្ញាក់ហើយឃើញដូច្នោះក៏ប្រញាប់សួរស្វាមីថា តើខ្ញុំម្ចាស់មានធ្វើអ្វីឲ្យទាស់ចិត្តឬមួយមានពាក្យសំដីខុសឆ្គងចំពោះព្រះអង្គទើបព្រះអង្គផ្ទុំមិនលក់យ៉ាងនេះ។ ពុទ្ធិសែនស្ដាប់ព្រមហេសីទូលសួរដូច្នោះក៏ប្រញាប់ឆ្លើយវិញថា:

គ្មាននរណាម្នាក់ធ្វើខុសចិត្តបងទេ ប្អូនកុំបារម្ភប៉ុន្តែបងនេះធ្លាប់នៅស្រុកឯនោះឧស្សាហ៍ទៅព្រៃក្រៅកំសាន្តណាស់ ប៉ុន្តែនៅទីនេះបងសែនអផ្សុកពេកក្រៃព្រោះនៅតែក្នុងរាជវាំងជារៀងរហូតមក។ កង្រីស្ដាប់ស្វាមីហើយក៏ទូលវិញថា:

សូមព្រះអង្គកុំព្រួយផ្ទុំវិញចុះ ថ្ងៃស្អែកយើងនឹងនាំគ្នាទៅសួនកំសាន្តរបស់នគរនេះ។ ស្អែកឡើង កង្រីនឹងស្វាមីក៏រៀបចំក្បួនដង្ហែរចេញទៅកំសាន្ត។ ធ្វើដំណើរអស់ពេលកន្លះថ្ងៃទើបទៅដល់ ហើយក៏នាំគ្នាបោះព្រះពន្លាសម្រាកនៅទីនោះ។ ពេលសោយអាហារថ្ងៃហើយ កង្រីក៏នាំពុទ្ធិសែនដើរមើលវត្ថុទិព្វរបស់នគរ។ ពុទ្ធិសែនឃើញស្គរមួយយ៉ាងធំធ្វល់ណាស់ក៏សួរនាងកង្រី នាងក៏ឆ្លើយវិញថា:

ស្គរនេះជាស្គរជ័យ ពេលគោះកាលណានឹងមានអាវុធចេញពីនោះយ៉ាងច្រើន ចុងក្រោយបង្អស់ពួកគេក៏ទៅដល់កន្លែងដាក់កែវភ្នែកនាង១២ ពុទ្ធិសែនក៏សួរថា:

តើនោះជាអ្វីទៅ?

ជាកែវភ្នែកនាងទាំង១២នាក់

អត្ថបទដោយ៖ មាស សុភាព

តើមានថ្នាំសម្រាប់ព្យាបាលដែរឬទេ?

ក្រាបទូលគឺនៅក្បែរនោះហើយ

ពុទ្ធិសែនសួរសព្វគ្រប់ ចំណែកនាងកង្រីមិនបានចាប់អារម្មណ៍ថានឹងមានរឿងអ្វីកើតឡើងទេ នាងឆ្លើយសុទ្ធតែការពិតទាំងអស់។ ពេលមកដល់ព្រះពន្ធារិញ ព្រះអង្គពុទ្ធិសែនក៏ចាត់វិធីស៊ីផឹក គឺចែកស្រា ឲ្យពួកអាមាត្រ និងកិលៀងផឹកគ្រប់ៗគ្នា ចំណែកព្រះអង្គបានបង្អកស្រានាងកង្រីរហូតទាល់តែស្រវឹងដោគហើយក៏ផ្ទុំលក់ភ្លាមទៅ ពួកកិលៀង និងអាមាត្រក៏ដូច្នោះដែរ នាំគ្នាស៊ីផឹករហូតដល់ដួលដេកទាំងអស់គ្នាគ្មាននៅសល់នរណាម្នាក់ឡើយ។ បានឱកាសល្អភ្លាមព្រះអង្គពុទ្ធិសែនក៏ប្រញាប់ចេញទៅយកកែវភ្នែក បេះថ្នាំស័ក្ដិសិទ្ធិ ហើយថែមទាំងយកស្គរជ័យទៅជាមួយផង។ យកបានសព្វគ្រប់ហើយ ព្រះអង្គក៏ត្រលប់មករកនាងកង្រីវិញ ហើយនិយាយថា:

កង្រីបងសុំលាមុនសិនហើយ ឲ្យបងសុំទោសផងចុះ បងនឹងវិលត្រឡប់មកវិញពេលដែលព្យាបាលមាតាបងហើយ បងមិនអាចបំភ្លេចប្អូនបានទេ ដោយរង់ចាំព្រះអង្គពុទ្ធិសែនយូរពេក មណីកែវក៏តឿនថា: ព្រះអង្គឆាប់ឡើង ហួសពេលឥឡូវហើយ។ មណីកែវតឿនម្ដងជាពីរដង ទើបពុទ្ធិសែនចេញបានបន្តិច កង្រីក៏ដឹងខ្លួនផ្ទាករកស្វាមី ស្រាប់តែបាត់សូន្យឈឹង នាងក៏ឆោឡោឡើង ពួកកិលៀង និងអាមាត្ររត់រកគ្រប់ទិសទីមិនឃើញ ទើបព្រះនាងដឹងថាប្រាកដជាពុទ្ធិសែនរត់ចោលនាងហើយ នាងក៏ប្រញាប់ចេញទៅមើលវត្ថុទិព្វ។ ពេលទៅដល់ស្រាប់តែភ្ញាក់ព្រើតព្រោះកែវភ្នែកនាងទាំង១២ គងជ័យ ព្រមទាំងវត្ថុជាច្រើនត្រូវបាត់អស់ នាងក៏ប្រមូលគ្នាចេញទៅភ្លាម។ ពេលដែលទ័ពយក្សតាមជិតទាន់ ពុទ្ធិសែនបានបោះផ្លែក្រូចទិព្វ ក៏ក្លាយជាភ្នំមួយយ៉ាងធំ ពេលនោះក៏បានកំទេចភ្នំហើយតាមទៅមុខទៀត។ ពុទ្ធិសែនបានបោះក្រូចជាលើកទី២ទៀត ក៏ក្លាយជាភ្នំយ៉ាងច្រើនជាន់ ទ័ពយក្សក៏បានកំទេចភ្នំនោះចោលទៀត ហើយតាមពុទ្ធិសែនយ៉ាងប្រកិតពេលនោះពុទ្ធិសែនក៏ប្រើស្គរជ័យ អាវុធជាច្រើនចេញមកព្រោងព្រាត កំទេចទ័ពយក្សស្លាប់អស់។ នាងកង្រីតាមពុទ្ធិសែន ឃើញទ័ពយក្សស្លាប់អស់យ៉ាងដូច្នេះ ក៏ស្រែកហៅស្វាមីថា: "ព្រះស្វាមីហេតុអ្វីក៏ព្រះអង្គដាច់ចិត្តទៅចោលខ្ញុំម្ចាស់នឹងបុត្រយ៉ាងនេះ បើព្រះអង្គមិនវិលវិញពេលនេះទេ ខ្ញុំម្ចាស់នឹងលាព្រះអង្គស្លាប់ហើយ"។ ព្រះអង្គពុទ្ធិសែនឮសំដី

កង្រីដូច្នោះចង់វិលចុះមកមើល តែត្រូវមណីកែវឃាត់ ទើបព្រះអង្គស្រែកប្រាប់វិញថា: "កង្រីប្អូនទៅសិនចុះ បងនឹងគង់ត្រឡប់មកវិញទេ ពេលនេះបងមិនអាចចុះទៅបានទេ"។ ពោលចប់សេះមណីកែវក៏ហោះទៅយ៉ាងលឿនសំដៅទៅនគរឥន្ទបត្ត។ គ្រាន់តែព្ទពុទ្ធិសែនចូលដល់នគរវិញភ្លាម សន្ធមារក៏បានដឹងរឿងទាំងអស់ ហើយក៏មានចិត្តក្រេវក្រោធយ៉ាងខ្លាំង ទ្រាំមិនបានសន្ធមារក៏ប្រែចេញរូបពិតភ្លាម ក្នុងគោលបំណងចង់សម្លាប់ពុទ្ធិសែនឲ្យបានក្នុងពេលនោះ ប៉ុន្តែពុទ្ធិសែនដឹងភ្លាមក៏ប្រញាប់យកស្គរជ័យមកគោះ អាវុធជាច្រើនបានចេញមក ហើយសម្លាប់ស្រីយក្សសន្ធមារភ្លាមមួយរំពេច។ ឃើញហេតុការដ៏គួរឲ្យរន្ធត់នោះ ព្រះអង្គរថសិទ្ធិក៏ស្ទុះទៅអោបបុត្រហើយមានបន្ទូលថា:"បុត្របិតាលើកទោសឲ្យបិតាផង នេះបិតាមិនបានដឹងថាជាស្រីយក្សទេ ស្មានតែជាស្រីដូចអស់គេ បិតាមានកំហុសធ្ងន់ណាស់ចំពោះមាតាបុត្រ"។ បន្ទាប់ពីរឿងរ៉ាវបានចប់សព្វគ្រប់ ព្រះអង្គរថសិទ្ធិក៏បានឲ្យបម្រើទៅទទួលនាង១២នាក់ចូលរាជវាំងវិញ ចំណែកពុទ្ធិសែនក៏បានយកកែវភ្នែកនឹងថ្នាំដាក់ព្យាបាលឲ្យមាតា និងម្តាយធំបានភ្លឺវិញទាំងអស់គ្នា ព្រះអង្គពុទ្ធិសែនក៏បានរៀបរាប់រឿងរ៉ាវដែលបានកើតឡើងទាំងអស់ប្រាប់ដល់មាតាបិតា ហើយក្រាបបង្គំលាទៅរកមហេសី និងបុត្រវិញ ប៉ុន្តែពេលទៅដល់ក៏ត្រូវស្រងេះស្រងោចខ្លោចចិត្តពេកក្រៃ ដោយឃើញនាងកង្រីដេកស្ងួកស្ពឹងក្នុងមឈូសកញ្ចក់ដែលតំកល់ទុក។ ព្រះអង្គពុទ្ធិសែនបានរៀបចំបញ្ចុះសពនឹងធ្វើបុណ្យរួចរាល់ហើយ ព្រះអង្គក៏រៀបអភិសេកឲ្យបុត្ររបស់ព្រះអង្គឡើយស្នងរាជជំនួសព្រះអង្គ ហើយព្រះអង្គក៏វិលត្រឡប់មករកមាតា និងបិតាវិញ។ ចំណោរក្រោយមក ព្រះអង្គរថសិទ្ធិក៏អភិសេកព្រះអង្គពុទ្ធិសែនឲ្យឡើងគ្រងរាជជំនួសព្រះអង្គ ហើយក៏រស់នៅយ៉ាងសុខសាន្តរៀងទៅ។

អត្ថបទដោយ៖ មាស សុភាព